# I - ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១

យើង

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីសហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ត្រាស់បង្គាប់**

**មាត្រា ១ :** គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើត និងរៀបរៀងតាមប្រភេទ និងតាមឋានានុក្រម ដូចខាងក្រោមនេះ ÷

ក - ប្រភេទមាតុប្រទេស :

១ - មេដាយជាតូបការៈ

២ - មេដាយព្រះរាជាណាចក្រកម្ពុជា មាន ៥ ថ្នាក់ : មហាសេរីវឌ្ឍន៍ មហាសេនា - ធិបឌិន្ទ - សេនា - អស្សប្ញទ្ធិ

៣ - មេដាយឯករាជជាតិ

គ្រឿងឥស្សរិយយសប្រភេទនេះ សំរាប់បំពាក់ជូនវរជនដែលមានគុណូបការៈដ៏ឧត្តុង្គឧត្តម ក្នុងការបំរើមាតុប្រទេស ដើម្បីបុព្វហេតុឯករាជ្យ សាមគ្គីភាព ប្រជាធិបតេយ្យ និង សន្តិភាពជាតិ តាមរយៈព្រះរាជក្រឹត្យក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយត្រូវប្រទានដោយព្រះមហាក្សត្រ ឬ ដោយព្រះរាជតំណាង ។

ខ - ប្រភេទព្រះរាជបល្ល័ង្ក

១ - មេដាយរាជសម្បត្តិ

២ - មេដាយ រដ្ឋកាល មាន ៣ ថ្នាក់ : មាស , ប្រាក់ , សំរិទ្ធ

៣ - មេដាយអនុស្សរា

គ្រឿងឥស្សរិយយសប្រភេទនេះ សំរាប់បំពាក់ជូនវរជនដែលមានគុណបំណាច់ចំពោះព្រះរាជបល្ល័ង្ក ចំពោះព្រះមហាក្សត្រផ្ទាល់ ចំពោះព្រះរាជវង្សានុវង្ស ព្រះមហាក្សត្រ ឬ ជាអនុស្សាវរីយ៍របស់ព្រះមហាក្សត្រ ។

ការផ្តល់ និង បំពាក់គ្រឿងឥស្សរិយយសទាំងនេះ ត្រូវសំរេចដោយព្រះរាជតំរិះផ្ទាល់របស់ព្រះមហាក្សត្រ តាមរយៈក្រឹត្យបរមរាជវាំង ។

គ - ប្រភេទការពារជាតិ :

១ - មេដាយសេនាជ័យសិទ្ធ

២ - មេដាយការពារជាតិ មាន ៣ ថ្នាក់ មាស ប្រាក់ សំរិទ្ធ

គ្រឿងឥស្សរិយយសទាំងនេះ សំរាប់បំពាក់ជូនដល់ពលទាហាន នាយទាហាន នៃ កងកម្លាំងប្រដាប់អាវុធ ឬ នគរបាលដែលមានស្នាដៃឆ្នើមពិសេសក្នុងសង្គ្រាម ឬកិច្ចការពារព្រំដែន និងការពារសន្តិសុខជូនជាតិមាតុភូមិ តាមរយៈព្រះរាជក្រឹត្យ ក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយត្រូវប្រទានដោយព្រះមហាក្សត្រ ឬ ព្រះរាជតំណាង ។

ឃ - ប្រភេទចំរុះ

១- មេដាយសហមេត្រី មាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនអគ្គទូត ឬតំណាងប្រទេសជាមិត្តដែលបានបំពេញការងារ ដើម្បីជាប្រយោជន៍ដល់ចំណងមិត្តភាពប្រទេសទាំងពីរ ។

២- មេដាយសុវត្ថារា មាន ៣ ថ្នាក់ : ធិបឌិន្ទ សេនា អស្សប្ញទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ក្នុងវិស័យ កសិកម្ម និងសេដ្ឋកិច្ច ។

៣- មេដាយមុនីសារាភ័ណ្ឌ មាន៣ ថ្នាក់ : ធិបឌិន្ទ សេនា អស្សប្ញទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ ក្នុងវិស័យសិក្សាធិការ អក្សរសាស្ត្រ វិទ្យាសាស្ត្រ វិចិត្រសិល្បៈ សង្គមកិច្ច ឬ វិស័យផ្សេង ៗ ទៀត ។

៤- មេដាយការងារមាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនបុគ្គលដែលមានថ្វីដៃក្នុងការងារផ្នែករដ្ឋបាល ឬ ក្នុងវិស័យឯកជន ។

៥- មេដាយស្ថាបនាជាតិមាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនសប្បុរសជន ដែលបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនជួយកសាងជាតិ ឬស្ថាបនា សមិទ្ធជាប្រយោជន៍សាធារណៈ ។

– មេដាយខេមរាកីឡាប្ញទ្ធិ មាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនកីឡាករដែលមានស្នាដៃឆ្នើមក្នុងវិស័យកីឡាជាតិ ឬអន្តរជាតិដែលបាននាំមកនូវកិត្តិយសដល់ប្រទេសជាតិ ។

– មេដាយស្ត្រីវឌ្ឍនា មាន ៣ ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សំរាប់បំពាក់ជូនស្ត្រី ឬ បុរសដែលមានគុណូបការៈខ្ពង់ខ្ពស់ក្នុងការលើកតំកើងបុព្វហេតុស្ត្រី ។

– គ្រឿងឥស្សរិយយសប្រភេទចំរុះនេះ ត្រូវរៀបចំតាមរយៈអនុក្រឹត្យ និងបំពាក់ដោយនាយករដ្ឋមន្ត្រី ឬ តំណាង ។

**មាត្រា ២** : រូបភាពលក្ខណៈសញ្ញាផ្សេង ៗ នៃ ឥស្សរិយយស និង ប្រកាសនីយបត្រ គ្រឿង ឥស្សរិយយសទាំងនេះត្រូវយកតាមគំរូដែលបានកំណត់ក្នុងព្រះរាជក្រឹត្យ ចុះ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៦៣ ។

**មាត្រា ៣** : រៀងរាល់ដំណាច់ឆ្នាំ អាជ្ញាធរមានសមត្ថកិច្ចតាមក្រសួង ឬ តាមអង្គភាពនីមួយៗ មានភារកិច្ចស្រង់បញ្ជីឈ្មោះវរជនដែលត្រូវស្នើរដ្ឋាភិបាល ដើម្បីសំរេចជូនមេដាយ ដោយមានបញ្ជាក់ផងដែរ នូវទឡ្ហីករណ៍ចំពោះករណីផ្ទាល់វរៈជនម្នាក់ ៗ ។ ក្នុងករណីពិសេសបន្ទាន់ និង ចាំបាច់នាយករដ្ឋមន្ត្រី អាចនឹងស្នើរៀបចំពីធីបំពាក់ឥស្សរិយយសនេះជាមុន រួចរៀបចំសំណុំបែបបទស្នើសុំជាខាងក្រោយ ។

**មាត្រា ៤** : គ្រឿងឥស្សរិយយស ពុំអាចផ្តល់ជូនឥស្សរជនមួយរូបលើសពីមួយដងក្នុងមួយឆ្នាំបានឡើយ ។ តែមេដាយការពារជាតិ ឬ មេដាយស្ថាបនាជាតិមិនត្រូវគិតបញ្ចូលទេ ។

**មាត្រា ៥** : រាជរដ្ឋាភិបាលត្រូវផលិតមេដាយ និង ត្រូវមានសារាចរលំអិតបន្ថែមទៀត ដើម្បីណែនាំដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ អំពីបែបបទ នៃការរៀបចំសំណើសុំគ្រឿងឥស្សរិយយស ។

**មាត្រា ៦** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧** : នាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៨** : ព្រះរាជក្រឹត្យនេះមានអានុភាពគតិយុត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

**ព្រះហស្ថលេខា** **ហត្ថលេខា**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

**ហត្ថលេខា**

**សុខ អាន** **វ៉េង សិរីវុឌ្ឍ**

* * *

# II - ទីស្ដីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៧២ អនក្រ.ក**

**ស្ដីពីការកែសំរួលនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ ឱ្យទៅជាអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ**